# ការគាំទ្រនានាដែលអ្នកអាចចំណាយប្រាក់ NDIS បាន

Khmer | ភាសាខ្មែរ

ងាយស្រួលអាន (Easy Read)



## ជំនួយជាមួយនឹងឯកសារនេះ



អ្នកអាចរកនរណាម្នាក់ឲ្យជួយអ្នកបាន៖

- យល់ដឹងពីឯកសារនេះ
- ស្វែងរកព័ត៌មានបន្ថែម។



ព័ត៌មានទំនាក់ទំនងមាននៅចុងបញ្ចប់នៃឯកសារនេះ។

# អំពីឯកសារនេះ

ទីភ្នាក់ងារធានារ៉ាប់រងជនពិការថ្នាក់ជាតិ (NDIA) បានសរសេរឯកសារនេះ។



នៅពេលយើងប្រើពាក្យថាយើង វាមានន័យថា NDIA។

យើងផ្តល់គម្រោងធានារ៉ាប់រងជនពិការថ្នាក់ជាតិ (National Disability Insurance Scheme) ឬ NDIS។



ឯកសារនេះនិយាយអំពីការគាំទ្រនានាដែលអ្នក**អាច** ចំណាយប្រាក់ NDIS បាន។

# ការគាំទ្រនានាដែលអ្នកអាចចំណាយប្រាក់ NDIS បាន

## ជំនួយសម្រាប់កន្លែងស្នាក់នៅ ឬជំនួយក្នុងការជួលផ្ទះ



កន្លែងស្នាក់នៅ ឬការជួលផ្ទះមានន័យថាកន្លែងដែលអ្នករស់នៅ។



ជំនួយមានន័យថាការជួយ។

អ្នក**អាច** ចំណាយប្រាក់ NDIS ទៅលើ៖



- ការគាំទ្រដើម្បីជួយស្វែងរកកន្លែងណាមួយដើម្បីរស់នៅ
- ការគាំទ្រដើម្បីស្នាក់នៅកន្លែងដែលអ្នកកំពុងរស់នៅ។

## សត្វជំនួយ



សត្វជំនួយមានន័យថា សត្វដែលត្រូវបានបណ្តុះបណ្តាលដើម្បីគាំទ្រដល់មនុស្សដែលមានពិការភាព។ ឧទាហរណ៍ ឆ្កែនាំផ្លូវ។



អ្នក**អាច** ចំណាយប្រាក់ NDIS លើសត្វជំនួយដែលមានសិទ្ធិទទួល។



សត្វជំនួយដែលមានសិទ្ធិទទួលគឺជាសត្វដែលបានទទួលការបណ្តុះបណ្តាលដែលបានធ្វើតេស្តជាប់។

## ជំនួយក្នុងការសម្របសម្រួល ឬគ្រប់គ្រងដំណាក់កាលជីវិត ការឆ្លងពីដំណាក់មួយទៅដំណាក់មួយទៀត និងការគាំទ្រនានា

ការសម្របសម្រួល ឬការគ្រប់គ្រង មានន័យថាការមើលថែ។



ដំណាក់កាលជីវិត និងការឆ្លងពីដំណាក់មួយទៅដំណាក់មួយទៀតមានន័យថានៅពេលដែលអ្វីទាំងឡាយមានការផ្លាស់ប្តូរក្នុងជីវិតរបស់អ្នក។

អ្នក**អាច**ចំណាយប្រាក់ NDIS លើបុគ្គលិកគាំទ្រ ដើម្បីគាត់បង្ហាញអ្នកពីរបៀបធ្វើកិច្ចការនានាដោយខ្លួនអ្នកបាន។

ឧទាហរណ៍ របៀប៖



- រើផ្ទះ
- ទៅជួបគេតាមការណាត់ជួប។

# ជំនួយក្នុងការទទួលបាន និងការរក្សាការងារ ឬការអប់រំឧត្តមសិក្សា

រក្សា មានន័យថា រក្សា។



ការអប់រំឧត្តមសិក្សាមានន័យថា ការអប់រំដែលធ្វើឡើង ក្រោយពីអ្នកបានបញ្ចប់វិទ្យាល័យហើយ។




អ្នក**អាច** ចំណាយប្រាក់ NDIS លើការគាំទ្រក្នុងការ៖



- ផ្លាស់ប្តូរពីវិទ្យាល័យទៅការអប់រំឧត្តមសិក្សា
- ស្វែងរកការងារ
- រក្សាការងារដែលអ្នកកំពុងធ្វើឥឡូវនេះ។

# ជំនួយក្នុងកិច្ចការរស់នៅប្រចាំថ្ងៃជាក្រុមមួយ ឬជាការចែកបន្ទប់គ្នារស់នៅក្នុងផ្ទះមួយ



ការរស់នៅជាក្រុម ឬការចែកបន្ទប់គ្នារស់នៅក្នុងផ្ទះមួយ មានន័យថាអ្នករស់នៅជាមួយមនុស្សដទៃទៀត។

អ្នក**អាច** ចំណាយប្រាក់ NDIS លើការគាំទ្រនានាដែលជួយអ្នកធ្វើកិច្ចការនានានៅក្នុងផ្ទះរបស់អ្នកបាន។





ឧទាហរណ៍ បុគ្គលិកគាំទ្រដែលអាចបង្ហាញអ្នកពីរបៀប៖

- ថែរក្សាខ្លួនអ្នក
- ធ្វើម្ហូប
- សម្អាតផ្ទះរបស់អ្នក។

## ជំនួយក្នុងការចាត់ចែងការធ្វើដំណើរ ឬការដឹកជញ្ជូន

អ្នក**អាច**ចំណាយប្រាក់ NDIS លើការធ្វើដំណើរ និងដឹកជញ្ជូន ប្រសិនបើអ្នក៖



- មិនអាចធ្វើដំណើរដោយខ្លួនឯងបានទេ
- មិនអាចប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈបានទេ។

ឧទាហរណ៍ អ្នកអាចប្រើប្រាស់ប្រាក់ NDIS របស់អ្នកមួយចំនួនដើម្បីជិះតាក់ស៊ីដើម្បី៖




- ទៅទទួលការគាំទ្រពី NDIS
- ទៅសាលារៀន
- ទៅធ្វើការ។

# ឧបករណ៍ជំនួយសម្រាប់ការកម្សាន្ត



ឧបករណ៍ជំនួយមានន័យថាអ្វីទាំងឡាយដែលត្រូវបានកែ ដើម្បីជួយអ្នកធ្វើអ្វីមួយ។

ការកម្សាន្តមានន័យថា អ្វីទាំងឡាយដែលអ្នកធ្វើដើម្បីសប្បាយ ដូចជាកីឡាជាដើម។



អ្នក**អាច**ចំណាយប្រាក់ NDIS ដើម្បីកែឧបករណ៍របស់អ្នក ដើម្បីឱ្យអ្នកអាចប្រើប្រាស់វាបាន។

## ផលិតផលជំនួយសម្រាប់កិច្ចការផ្ទះ

ផលិតផលជំនួយសម្រាប់កិច្ចការផ្ទះមានន័យថាអ្វីទាំងឡាយដែលត្រូវបានកែ ដើម្បីឱ្យអ្នកអាចប្រើប្រាស់វាបាន។

ឧទាហរណ៍ អ្វីមួយដែលត្រូវបានកែដើម្បីជួយអ្នកធ្វើការងារនានាដូចជា៖



- សម្អាតផ្ទះរបស់អ្នក
- ធ្វើម្ហូប។



អ្នក**អាច**ចំណាយប្រាក់ NDIS ដើម្បីកែអ្វីទាំងឡាយដែលអ្នកត្រូវការក្នុងការធ្វើការងារនានានៅជុំវិញផ្ទះរបស់អ្នក។

# ផលិតផលជំនួយសម្រាប់ការថែទាំ និងសុវត្ថិភាពផ្ទាល់ខ្លួន



អ្នក**អាច**ចំណាយប្រាក់ NDIS លើអ្វីនានាដូចជា៖

- ផលិតផលសម្រាប់បង្គន់ និងបន្ទប់ទឹកខុសៗគ្នា
- សម្លៀកបំពាក់ និងគ្រឿងសង្ហារិមដែលជួយបំពេញតម្រូវការរបស់អ្នក។

## ឧបករណ៍ទំនាក់ទំនង និងព័ត៌មាន



ឧបករណ៍ទំនាក់ទំនង និងព័ត៌មាន មានន័យថាអ្វីទាំងឡាយដែលអាច៖

- ជួយអ្នកឱ្យទទួលបានព័ត៌មាន
- ជួយអ្នកក្នុងការផ្តល់ព័ត៌មានដល់មនុស្សដទៃទៀត។



ឧទាហរណ៍ក្តារទំនាក់ទំនង។

អ្នក**អាច**ចំណាយប្រាក់ NDIS លើអ្វីទាំងឡាយដែលអាចជួយអ្នកក្នុងការ៖



- ធ្វើទំនាក់ទំនង
- ទទួលបានព័ត៌មានដែលអ្នកត្រូវការ។

## ការថែទាំពីគិលានុបដ្ឋាយិកាសហគមន៍



ការថែទាំពីគិលានុបដ្ឋាយិកាសហគមន៍មានន័យថា អ្នកទទួលបានការថែទាំនៅក្នុងផ្ទះរបស់អ្នក។

អ្នក**អាច**ចំណាយប្រាក់ NDIS លើការថែទាំពីគិលានុបដ្ឋាយិកាសហគមន៍ ប្រសិនបើអ្នកត្រូវការការថែទាំពីមនុស្សដែលមានការបណ្ដុះបណ្ដាលពិសេស។



ឧទាហរណ៍ អ្នកត្រូវការគិលានុបដ្ឋាយិកាដែលមានការបណ្ដុះបណ្ដាលពិសេសដើម្បីគ្រប់គ្រងឱសថរបស់អ្នក។

# ផ្នែករូបកាយសិប្បនិម្មិត និងគ្រឿងសម្រាប់ទ្រទប់ខ្លួនកុំឱ្យទ្រេត តាមតម្រូវការរបស់បុគ្គល



តាមតម្រូវការរបស់បុគ្គលមានន័យថា អ្វីមួយដែលបានផលិតឡើងសម្រាប់តែមនុស្សម្នាក់ប៉ុណ្ណោះ។



ផ្នែករូបកាយសិប្បនិម្មិត មានន័យថាផ្នែករាងកាយដែលបានផលិតដោយមនុស្ស។



គ្រឿងសម្រាប់ទ្រទប់ខ្លួនកុំឱ្យទ្រេត មានន័យថារបស់នានាដែលទ្រទ្រង់រាងកាយរបស់អ្នក ដូចជាដៃ ឬជើងរបស់អ្នក។

អ្នក**អាច**ចំណាយប្រាក់ NDIS ទៅលើផ្នែករូបកាយសិប្បនិម្មិត ឬគ្រឿងសម្រាប់ទ្រទប់ខ្លួនកុំឱ្យទ្រេត តាមតម្រូវការរបស់បុគ្គល។

## សកម្មភាពផ្ទាល់ខ្លួនប្រចាំថ្ងៃ



សកម្មភាពផ្ទាល់ខ្លួនប្រចាំថ្ងៃមានន័យថាអ្វីទាំងឡាយដែលអ្នកត្រូវធ្វើជារៀងរាល់ថ្ងៃ។ ឧទាហរណ៍ងូតទឹក។

អ្នក**អាច**ចំណាយប្រាក់ NDIS ដើម្បីគាំទ្រអ្នកក្នុងការធ្វើអ្វីទាំងឡាយដែលអ្នកត្រូវធ្វើជារៀងរាល់ថ្ងៃ។

## ការបង្កើតការថែទាំប្រចាំថ្ងៃ និងជំនាញសម្រាប់ជីវិត



ការថែទាំប្រចាំថ្ងៃ និងជំនាញសម្រាប់ជីវិត មានន័យថាអ្នកអាចមានភាពឯករាជ្យជាងមុន។

អ្នក**អាច**ចំណាយប្រាក់ NDIS បានដើម្បីជួយអ្នករៀនពីជំនាញក្នុងការថែទាំប្រចាំថ្ងៃ និងជំនាញសម្រាប់ជីវិត។

## ការគាំទ្រសុខភាពទាក់ទងនឹងពិការភាព

ការគាំទ្រសុខភាពទាក់ទងនឹងពិការភាព គឺជាការគាំទ្រនានា ដែលអ្នកត្រូវការដើម្បីជួយអ្នកឱ្យដំណើរការជារៀងរាល់ថ្ងៃ។



ឧទាហរណ៍ អ្នកប្រហែលជាមានការពិបាកលេប ហើយ ត្រូវការសមស្លាព្រាពិសេសដើម្បីជួយអ្នកក្នុងការបរិភោគ។



អ្នក**អាច**ចំណាយប្រាក់ NDIS លើការគាំទ្រសុខភាពទាក់ទង នឹងពិការភាព។

## ការគាំទ្រក្នុងការឆាប់ធ្វើអន្តរាគមន៍សម្រាប់កុមារវ័យក្មេង



កុមារវ័យក្មេងមានន័យថាកុមារទាំងឡាយដែល៖

- មានអាយុក្រោម 6 ឆ្នាំដែលលូតលាស់យឺតជាងកុមារដទៃទៀត
- មានអាយុក្រោម 9 ឆ្នាំ ហើយមានពិការភាព។



លូតលាស់ មានន័យថារបៀបដែលកុមារលូតលាស់ និងរៀនសូត្រ។



អ្នក**អាច**ចំណាយប្រាក់ NDIS លើការគាំទ្រកុមារវ័យក្មេង ដូចជា ការព្យាបាលដើម្បីជួយកុមារ៖

- ធ្វើទំនាក់ទំនង
- រៀនសូត្រ។

## ការហាត់ប្រាណ សរីរវិទ្យា និងសកម្មភាពសម្រាប់សុខុមាលភាពផ្ទាល់ខ្លួន



សរីរវិទ្យាមានន័យថារបៀបដែលរាងកាយរបស់អ្នកដំណើរការ។

សុខុមាលភាពមានន័យថាអ្នកមានសុខភាពល្អ និងសុខសប្បាយ។

អ្នក**អាច**ចំណាយប្រាក់ NDIS លើវត្ថុនានាដែលជួយឱ្យអ្នកមានសុខភាពល្អ និងសុខសប្បាយ។



ឧទាហរណ៍ ដើម្បីបង់ថ្លៃឱ្យអ្នកមានវិជ្ជាជីវដើម្បីជួយអ្នក៖

- ផ្លាស់ទី
- រក្សាឲ្យនៅតែរឹងមាំ។

## សកម្មភាពផ្អែកលើក្រុម និងមជ្ឈមណ្ឌល



ផ្អែកលើមជ្ឈមណ្ឌលមានន័យថាជាកន្លែងដែលមនុស្សទៅដើម្បីធ្វើសកម្មភាពជាមួយគ្នា។ ឧទាហរណ៍ មជ្ឈមណ្ឌលសហគមន៍។

អ្នក**អាច**ចំណាយប្រាក់ NDIS លើសកម្មភាពផ្អែកលើក្រុម និងមជ្ឈមណ្ឌល។

## ឧបករណ៍ការស្តាប់



អ្នក**អាច**ចំណាយប្រាក់ NDIS លើវត្ថុមួយចំនួនដែលអាចជួយឱ្យអ្នកស្តាប់ឮ។

## សកម្មភាពផ្ទាល់ខ្លួនប្រចាំថ្ងៃដែលមានការខំប្រឹងខ្ពស់

សកម្មភាពផ្ទាល់ខ្លួនប្រចាំថ្ងៃមានន័យថាជាអ្វីទាំងឡាយដែលអ្នកត្រូវតែធ្វើ ជារៀងរាល់ថ្ងៃ។



អ្នកប្រហែលជាត្រូវការ៖

- មនុស្សជាច្រើនដើម្បីជួយអ្នក
- ឧបករណ៍ពិសេសដើម្បីជួយអ្នក។



អ្នក**អាច**ចំណាយប្រាក់ NDIS បានដើម្បីជួយអ្នកក្នុងការធ្វើសកម្មភាពទាំងនេះ។

## ការរចនាការកែប្រែ និងការសាងសង់ផ្ទះ





ការរចនាការកែប្រែ និងសាងសង់ផ្ទះមានន័យថាតើផ្ទះរបស់អ្នកត្រូវ៖

- កែរបៀបម៉េចដើម្បីគាំទ្រពិការភាពរបស់អ្នក
- ធ្វើផែនការរបៀបម៉េចដើម្បីគាំទ្រពិការភាពរបស់អ្នក
- សាងសង់របៀបម៉េចដើម្បីគាំទ្រពិការភាពរបស់អ្នក។

អ្នក**អាច**ចំណាយប្រាក់ NDIS ដើម្បីធ្វើឱ្យវាកាន់តែងាយស្រួលក្នុងការរស់នៅក្នុងផ្ទះរបស់អ្នក។



ឧទាហរណ៍ ដើម្បីបង់សម្រាប់ការផ្លាស់ប្តូរនានាដែលជួយឲ្យអ្នកមានឯករាជភាពនៅក្នុងផ្ទះរបស់អ្នក។

## កិច្ចការផ្ទះ



អ្នក**អាច**ចំណាយប្រាក់ NDIS លើអ្វីទាំងឡាយដែលអ្នកត្រូវការជំនួយ ដោយសារពិការភាពរបស់អ្នក។



ឧទាហរណ៍៖

- ការដាំស្ល

- ការសម្អាត



- ធ្វើការបោកគក់។

## ការចូលរួមសហគមន៍ប្រកបដោយភាពច្នៃប្រឌិត



ការចូលរួមសហគមន៍ប្រកបដោយភាពច្នៃប្រឌិតមានន័យថា ជាការគាំទ្រសម្រាប់មនុស្សដែលមានតម្រូវការច្រើន។

វាជួយមនុស្សដែលមានតម្រូវការច្រើនឱ្យចូលរួមក្នុង ការរស់នៅក្នុងសហគមន៍។

## ការបកប្រែភាសាផ្ទាល់មាត់ និងសរសេរ

ការបកប្រែភាសាផ្ទាល់មាត់និងសរសេរមានន័យថា អ្នកទទួល បានព័ត៌មានជា៖



- ភាសាដែលអ្នកយល់
- ក្នុងទម្រង់ដែលអ្នកយល់។



អ្នក**អាច**ចំណាយប្រាក់ NDIS លើសេវាបកប្រែភាសា ផ្ទាល់មាត់ និងសរសេរបាន។

## ការគ្រប់គ្រងមូលនិធិសម្រាប់ការគាំទ្រនានា



ការគ្រប់គ្រងមូលនិធិសម្រាប់ការគាំទ្រនានាមានន័យថាមាននរណាម្នាក់មើលការខុសត្រូវលើមូលនិធិ NDIS ឲ្យអ្នក។

អ្នក**អាច**ចំណាយមូលនិធិ NDIS ទៅលើអ្នកគ្រប់គ្រងផែនការបាន។



អ្នកគ្រប់គ្រងផែនការអាច៖

- ស្វែងរកការគាំទ្រនានាសម្រាប់អ្នក
- បង់ប្រាក់ឱ្យជនដែលផ្តល់សេវាកម្មឱ្យអ្នក។

## ការចូលរួមក្នុងសកម្មភាពសហគមន៍ សកម្មភាពសង្គម និងសកម្មភាពពលរដ្ឋ



អ្នក**អាច**ចំណាយមូលនិធិ NDIS ទៅលើការគាំទ្រដើម្បីចូលរួមក្នុងសកម្មភាពនានា។

## ឧបករណ៍សម្រាប់ធ្វើឲ្យមនុស្សចល័តបាន



អ្នក**អាច**ចំណាយមូលនិធិ NDIS ទៅលើឧបករណ៍សម្រាប់ធ្វើឲ្យមនុស្សចល័តបាន។ ឧទាហរណ៍ រទេះសម្រាប់មនុស្សទប់ដើរ។

## កន្លែងស្នាក់នៅសម្រាប់ជនពិការពិសេស



កន្លែងស្នាក់នៅសម្រាប់ជនពិការពិសេស ឬ SDA មានន័យថាផ្ទះសម្រាប់អ្នកដែលមានតម្រូវការច្រើន។

អ្នក**អាច**ចំណាយប្រាក់ NDIS លើ SDA បាន។

## ការបង្ហាត់អ្នកបើកបរពិសេស



ការបង្ហាត់អ្នកបើកបរពិសេសមានន័យថា៖

- អ្នករៀនប្រើឧបករណ៍ពិសេសដើម្បីបើកបរ
- អ្នករៀនបើករថយន្តពិសេស។



អ្នក**អាច**ចំណាយប្រាក់ NDIS លើការបង្ហាត់អ្នកបើកបរពិសេសបាន។

## សេវាការស្ដាប់ពិសេស



សេវាស្ដាប់ពិសេស គឺជាសេវាស្ដាប់សម្រាប់មនុស្សដែលមានតម្រូវការច្រើន។

អ្នក**អាច**ចំណាយប្រាក់ NDIS លើសេវាស្ដាប់ពិសេសមួយចំនួនបាន។

# ការគាំទ្រពីអ្នកឯកទេសសម្រាប់អាកប្បកិរិយាវិជ្ជមាន

អ្នក**អាច**ចំណាយប្រាក់ NDIS លើការគាំទ្រពីអ្នកឯកទេសសម្រាប់អាកប្បកិរិយាវិជ្ជមានបាន។

ការគាំទ្រពីអ្នកឯកទេសសម្រាប់អាកប្បកិរិយាវិជ្ជមាន មានន័យថាមនុស្សដែលមានការបណ្តុះបណ្តាលពិសេស ដើម្បីជួយ ប្រសិនបើអ្នក៖



- ធ្វើកិច្ចការនានាដែលមិនមានសុវត្ថិភាពសម្រាប់អ្នក
- ធ្វើកិច្ចការនានាដែលមិនមានសុវត្ថិភាពសម្រាប់អ្នកដទៃ។

## ការងារដែលមានការគាំទ្រពីអ្នកឯកទេស



ការងារដែលមានការគាំទ្រពីអ្នកឯកទេសមានន័យថាជំនួយ ដើម្បីទទួលបានការងារប្រសិនបើ៖

- អ្នកមានតម្រូវការច្រើន
- អ្នកត្រូវការការគាំទ្រច្រើននៅពេលអ្នកនៅកន្លែងធ្វើការ។



អ្នក**អាច**ចំណាយប្រាក់ NDIS លើការងារដែលមានការគាំទ្រពីអ្នកឯកទេសបាន។

## ការសម្របសម្រួលការគាំទ្រ

ការសម្របសម្រួលការគាំទ្រ មានន័យថាអ្នកទទួលបានជំនួយបន្ថែមក្នុងការភ្ជាប់ទំនាក់ទំនងជាមួយ៖



- គ្រួសាររបស់អ្នក
- មិត្តភក្តិរបស់អ្នក
- ការគាំទ្ររបស់សហគមន៍ និងការគាំទ្ររបស់ NDIS។



អ្នក**អាច**ចំណាយប្រាក់ NDIS លើការសម្របសម្រួលការគាំទ្រពីអ្នកឯកទេសបាន។

## ការគាំទ្រតាមការព្យាបាល

ការគាំទ្រទាក់ទងនឹងការព្យាបាលជួយមនុស្សឱ្យ៖



- ធ្វើទំនាក់ទំនង
- ធ្វើដំណើរទៅនេះទៅនោះ
- មានភាពឯករាជ្យ។

អ្នក**អាច**ចំណាយប្រាក់ NDIS លើការគាំទ្រតាមការព្យាបាលបាន។

## ការកែប្រែយានយន្ត



ការកែយានយន្តមានន័យថាកំណែរថយន្តរបស់អ្នកដែល៖

- ជួយអ្នកក្នុងការបើកបរ
- ចូលទៅក្នុងរថយន្ត។

អ្នក**អាច**ចំណាយប្រាក់ NDIS លើការកែយានយន្តបាន។

## ឧបករណ៍ចក្ខុ

អ្នក**អាច** ចំណាយប្រាក់ NDIS លើឧបករណ៍ចក្ខុបាន។



ឧបករណ៍ចក្ខុ មានន័យថារបស់នានាដែលអាចជួយអ្នកមើលឃើញ ឬអានបាន។



ឧទាហរណ៍៖

- អក្សរស្ទាប
- កែវពង្រីក។



កែវពង្រីកធ្វើឱ្យរបស់នានាមើលទៅឃើញធំ។

## ព័ត៌មានបន្ថែមអំពីឯកសារនេះ

សម្រាប់ព័ត៌មានបន្ថែមអំពីឯកសារនេះ សូមទាក់ទងមកយើង។



### អ្នកអាចហៅទូរសព្ទមកយើងបាន

1800 800 110





### អ្នកអាចផ្ញើអ៊ីមែលមកយើង

enquiries@ndis.gov.au



### អ្នកអាចមកកាន់ការិយាល័យរបស់យើងផ្ទាល់បាន

អ្នកអាចស្វែងរកការិយាល័យក្នុងតំបន់របស់អ្នកនៅលើគេហទំព័រ NDIS។

ndis.gov.au/contact/locations

# ស្វែងយល់បន្ថែមទៀតអំពី NDIA




## ចូលមើលគេហទំព័ររបស់យើង

ndis.gov.au

## តាមដានយើងនៅលើបណ្ដាញសង្គមរបស់យើង

Facebook, Twitter, Instagram,

YouTube, LinkedIn

# រកជំនួយដើម្បីទាក់ទងមកយើង

## សម្រាប់អ្នកដែលត្រូវការជំនួយជាភាសាអង់គ្លេស



អ្នកអាចហៅទូរសព្ទទៅសេវាកម្មបកប្រែភាសាសរសេរ និងផ្ទាល់មាត់ (TIS)។

131 450

## សម្រាប់មនុស្សថ្លង់ ឬពិបាកស្តាប់




អ្នកអាចប្រើប្រាស់សេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ (National Relay Service)

relayservice.gov.au



អ្នកអាចប្រើមុខងារទូរសព្ទជាអក្សរ (TTY) បាន។

1800 555 677



អ្នកអាចប្រើការបញ្ជូនបន្តជាសំឡេងបាន។

1800 555 727

ឯកសារងាយស្រួលអាននេះត្រូវបានបង្កើតឡើងដោយក្រុមហ៊ុន Scope (Aust) Ltd. ក្នុងខែវិច្ឆិកា ឆ្នាំ 2024 ដោយប្រើនិមិត្តសញ្ញាទំនាក់ទំនងតាមរូបភាព (PCS)។ PCS គឺជាពាណិជ្ជសញ្ញារបស់ Tobii Dynavox, LLC។ រក្សាសិទ្ធិគ្រប់យ៉ាង។ ប្រើប្រាស់ដោយមានការអនុញ្ញាត។ ឯកសារនេះមិនត្រូវលក់ទៅឱ្យភាគីទីបីទេ។ រូបភាពនានានោះមិនត្រូវប្រើប្រាស់ឡើងវិញដោយគ្មានការអនុញ្ញាតឡើយ។ សម្រាប់ព័ត៌មានបន្ថែមអំពីរូបភាពនានានោះ សូមទាក់ទងក្រុមហ៊ុន Scope តាមលេខ 1300 472 673 ឬចូលមើលគេហទំព័រ scopeaust.org.au